# ជូនចំពោះរាល់កម្មសិក្សាការីហ្វឹកហ្វឺនជំនាញ

## ករណីមានផលវិបាកសូមពិគ្រោះ !

មណ្ឌលយើងខ្ញុំនឹងជួយពិគ្រោះជាភាសាជាតិដើម្បីអោយជីវភាពនឹងសុខមាលភាពក្នុងការហ្វឹកហ្វឺនជំនាញនៅប្រទេសជប៉ុនរបស់លោកអ្នកមានភាពល្អប្រសើរ។

【ពិគ្រោះយោបល់ជាភាសាជាតិ】https://www.support.otit.go.jp/soudan/kh/ → ផែបសាយ

## ● ចង់បន្តការហ្វឹកហ្វឺនក៏ប៉ុន្តែមិនអាចបន្តបាន…

ករណីមានការបង្ខំអោយត្រលប់ទៅស្រុកកំណើតវិញទាំងអ្នកនៅមានឆន្ទះបន្តការហ្វឹកហ្វឺនជំនាញ។

<u>សូមទាក់ទងមកមណ្ឌលយើងខ្ញុំអោយបានឆាប់រហ័ស</u>(ក្នុងករណីក្រោយទៅដល់អាកាសយានដ្ឋានឬកំពង់ផែសូមពិគ្រោះជាមួយប៉ូលីសអន្តោប្រវេសន៍)

**<u>ហើយប្រសិនបើ អ្នកមានផលលំបាកអំពីបញ្ហាត្រូវបានក្រុមហ៊ុនទទួលសិក្ខាកាមបញ្ឈប់ពីការងារដោយចោទថាជាហេតុផលផ្ទាល់ខ្លួន សូមទាក់ទងមកមណ្ឌលពិគ្រោះយោបល់ជាភាសាជាតិជាមុនសិន។</u>**

**សហជីពមានកាតព្វកិច្ចជួយរកក្រុមហ៊ុនថ្មីអោយកម្មសិក្សាការីណាដែលចង់បន្តការហ្វឹកហ្វឺនដល់ចប់។មិនត្រូវបញ្ជូនទៅស្រុកកំណើតវិញទាំងពាក់កណ្ដាលទីនោះទេ។

បើសហជីពមិនអាចរកការងាថ្មីអោយកម្មសិក្សាការីបានទេអង្គការនឹងជួយរក។

## ● ខុសខ្លឹមសារនៃការងារនឹងការមិនគោរពតាមកិច្ចសន្យា

ខ្លឹមសារនៃការងារខុសគ្នាក្នុងការពន្យល់មុនមកកាន់ស្រុកជប៉ុន។ប្រាក់ខែបានខុសពីកិច្ចសន្យា។មិនបានទទួលប្រាក់ថែមម៉ោង។ករណីរងអំពើហឹង្សាឬរងការធ្វើបាបគឺបាននយ័ថាល្មើសច្បាប់ហ្វឹកហ្វឺនជំនាញ។

<u>សូមទាក់ទងមកមណ្ឌលយើងខ្ញុំអោយបានឆាប់រហ័ស។</u>

## ● នឹងអាចទទួលប្រាក់ខែថ្លៃជាងនេះ

បើមានការផ្សព្វផ្សាយតាមSNSឬកាសែតស្វែងរកបុគ្គលិកឬក៏មានអ្នកស្គាល់គ្នាលួងលោមថា

"បើផ្លាស់ប្តូរការងារផ្សេងអាចបានប្រាក់ខែថ្លៃ", "អាចបើកប្រាក់ខែមុនថ្ងៃកំណត់", "មានការរ៉ាប់រងសុខមាលភាពខ្ពស់"

សូមកុំឆាប់ជឿអោយសោះ។អ្នកនឹងអាចត្រូវគេអូសទាញចូលក្នុងឧក្រិដ្ឋកម្មឬត្រូវគេកេងប្រវ័ញ្ចលើប្រាក់របស់អ្នក។

បើជួបរឿងទាំងអស់នេះ<u>សូមទាក់ទងមកមណ្ឌលយើងខ្ញុំ</u>អោយបានឆាប់រហ័ស។

បើលោកអ្នកគិតគូរតែម្នាក់ឯងហើយជឿតាមការលួងលោមរបស់អ្នកដ៏ទៃព្រមទាំងរត់គេចខ្លួនចេញពីក្រុមហ៊ុនអ្នកនឹងក្លាយជាជនខុសច្បាប់ដែលអាចងាយស្រួលក្នុងការអូសទាញចូលក្នុងឧក្រិដ្ឋកម្ម។

ករណីមានផលវិបាកផ្សេងៗ 「សូមទាក់ទងនឹងមណ្ឌលពិគ្រោះយោបល់ជាភាសាជាតិ」 អោយបានឆាប់រហ័ស !